# ការបញ្ចូលគ្នានៃច្បាប់សិទ្ធិមូលដ្ឋានរបស់អ្នក ជម្ងឺចុងក្រោយនៃរដ្ឋ Minnesota និងរដ្ឋសហព័ន្ធ ច្បាប់សិទ្ធិមូលដ្ឋាននៃជីវិតចុងក្រោយរបស់អ្នកជម្ងឺនៃរដ្ឋ Minnesota ក្នុងច្បាប់ MINNESOTA ផ្នែក 144A.751

ភាសាដែលសរសេរ **ដោយអក្សរដិត** បង្ហាញពីសិទ្ធិអ្នកប្រើប្រាស់បន្ថែម តាមច្បាប់នៃរដ្ឋសហព័ន្ធសម្រាប់អ្នកជម្ងឺនៃគម្រោងធានារ៉ាប់រងសុខភាពបានបញ្ជាក់ដោយអ្នកជម្ងឺដែលស្ថិតក្នុងជីវិតចុងក្រោយ ។

អនុផ្នែកទី 1 នៃសេចក្តីប្រកាសអំពីសិទ្ធិ ។ បុគ្គលដែលទទួលការថែទាំនូវជីវិតចុងក្រោយមានសិទ្ធិ៖

**ត្រូវបានជូនដំណឹងអំពីសិទ្ធិរបស់ខ្លួន និងមណ្ឌលថែទាំជិវិតចុងក្រោយនៃអ្នកជម្ងឺត្រូវការពារ និងលើកស្ទួយការអនុវត្តសិទ្ធិទាំងនេះ ។**

(1) **ត្រូវអនុវត្តសិទ្ធិរបស់ខ្លួនជាអ្នកជម្ងឺ ដែលត្រូវថែទាំចុងក្រោយនៃជីវិត ។** ទទួលបានព័ត៌មានជាលាយលក្ខណ៍អក្សរអំពីសិទ្ធិ មុនពេលការទទួលការថែទាំជីវិតចុងក្រោយ ឬក្នុងពេលពិនិត្យវាយតម្លៃលើកដំបូង មុនពេលចាប់ផ្តើមការថែទាំ រួមទាំងអ្វីដែលត្រូវបំពេញបើសិទ្ធិត្រូវបានរំលោភបំពាន ។

**សេចក្តីជូនដំណឹងអំពីសិទ្ធិ និងការទទួលខុសត្រូវ៖ (1) ក្នុងពេលពិនិត្យវាយតម្លៃលើកដំបូងមុនពេលថែទាំ មណ្ឌលត្រូវផ្តល់អ្នកជម្ងឺ ឬអ្នកតំណាង ដោយផ្ទាល់មាត់ (ដោយនិយាយប្រាប់) និងការជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីសិទ្ធិ និងការទទួលខុសត្រូវរបស់អ្នកជម្ងឺជាភាសាដែលអ្នកជម្ងឺអាចយល់បាន (2) មណ្ឌលត្រូវអនុវត្តតាមលក្ខខណ្ឌនៃអនុផ្នែកទី I នៃផ្នែកក្រមនៃបទប្បញ្ញត្តិរដ្ឋសហព័ន្ធ (CFR) 489 នៃជំពូកនេះទាក់ទងនឹងការណែនាំជាមុន ។ មន្ទីរពេទ្យត្រូវជូនដំណឹង និងចែកចាយព័ត៌មានជាលាយលក្ខណ៍អក្សរទៅអ្នកជម្ងឺទាក់ទងនឹងគោលនយោបាយរបស់ខ្លួនស្តីពីការណែនាំជាមុន រួមមានការរៀបរាប់អំពីច្បាប់ជាធរមានរបស់រដ្ឋ (3) មន្ទីរពេទ្យត្រូវយកហត្ថលេខារបស់អ្នកជម្ងឺ ឬអ្នកតំណាង ដើម្បីបញ្ជាក់ថាគាត់បានទទួលច្បាប់ចម្លងនៃការជូនដំណឹងអំពីសិទ្ធិ និងការទទួលខុសត្រូវនេះហើយ ។**

(2) ការទទួលសេវាកម្ម និងការថែទាំគឺអាស្រ័យភាពសមស្របនៃផែនការថែទាំរបស់មន្ទីរពេទ្យ និងត្រូវទទួលយកស្តង់ដានៃមន្ទីរពេទ្យ ហើយត្រូវសកម្មក្នុងការបង្កើត និងផ្លាស់ប្តូរផែនការ និងការវាយតម្លៃការថែទាំ និងការផ្តល់សេវា ។ **ត្រូវជាប់ទាក់ទងក្នុងការអភិវឌ្ឍផែនការថែទាំរបស់មន្ទីរពេទ្យ ។**

(3) ត្រូវបានប្រាប់ជាមុនអំពីការទទួលការថែទាំអំពីសេវាកម្ម ដែលនឹងត្រូវផ្តល់ឲ្យបទវិន័យ ដែលនឹងអនុវត្តចំពោះការថែទាំ ការសួរសុខទុក្ខតាមសំណើដែលបានដាក់ជម្រើសផ្សេងទៀត ដែលអាចនឹងមានផលវិបាកនៃជម្រើសទាំងនេះ រួមទាំងផលវិបាកនៃការបដិសេធនូវសេវាទាំងនេះផងដែរ ។

(4) ត្រូវបានប្រាប់ជាមុន បើអាច អំពីការផ្លាស់ប្តូរណាមួយក្នុងផែនការថែទាំមន្ទីរពេទ្យ និងត្រូវសកម្មក្នុងការផ្លាស់ប្តូរណាមួយនោះ ។

(5) បដិសេធ **ការថែទាំ**សេវាកម្ម ឬការព្យាបាល។

(6) ដឹងជាមុននូវការកម្រិតណាមួយចំពោះសេវាកម្មដែលមានពីអ្នកផ្តល់ ហើយមូលដ្ឋានរបស់អ្នកផ្តល់សេវាសម្រាប់បញ្ចប់សេវាកម្ម ។ **ទទួលព័ត៌មានអំពី វិសាលភាពនៃសេវាកម្មដែលមន្ទីរពេទ្យនឹងផ្តល់ ហើយកម្រិតយ៉ាងជាក់លាក់លើសេវាកម្មទាំងនោះ ។**

(7) ដឹងជាមុនអំពីការទទួលការថែទាំ ទោះបីជាសេវាកម្មមន្ទីរពេទ្យអាចគ្របដណ្តប់ដោយការធានារ៉ាប់រងសុខភាព ជំនួយសុខភាពសង្គម កម្មវិធីធានារ៉ាប់រងសុខភាព ឬកម្មវិធីសុខភាពផ្សេងទៀត ដែលបុគ្គលនោះបានចុះឈ្មោះ ។ **ទទួលព័ត៌មានអំពីសេវាកម្មដែលគ្របដណ្តប់ដោយប្រយោជន៍នៃមន្ទីរពេទ្យ ។**

(8) តាមការស្នើសុំទទួលការវាយតម្លៃ ដោយសុចរិតអំពីសំណង ដែលអ្នកផ្តល់សេវាសង្ឃឹមថានឹងទទួលពីកម្មវិធីសុខភាពដែលបុគ្គលនោះបានចុះឈ្មោះ ។ ការវាយតម្លៃសុចរិតក៏ត្រូវមានតាមសំណើរបស់បុគ្គលដែលមិនបានចុះឈ្មោះក្នុងគម្រោងសុខភាពនេះដែរ ។ ព័ត៌មានទូទាត់នេះមិនបង្កើតការប៉ាន់ប្រមាណជាប់កាតព្វកិច្ចតាមច្បាប់នៃតម្លៃសេវាកម្មនោះទេ ។

(9) ដឹងថាអាចនឹងមានសេវាកម្មផ្សេងទៀតក្នុងសហគមន៍ រួមទាំងសេវាកម្មសម្រាប់ចុងក្រោយនៃជីវិត និងអ្នកផ្តល់សេវាកម្មមន្ទីរពេទ្យផ្សេងទៀត និងដឹងថាទៅរកព័ត៌មានអំពីសេវាកម្មទាំងនោះនៅឯណា ។

(10) ជ្រើសរើសដោយសេរីក្នុងចំណោមអ្នកផ្តល់សេវាដែលមាន និងផ្លាស់ប្តូរអ្នកផ្តល់សេវាក្រោយពីបានចាប់ផ្តើមសេវាកម្មក្នុងកម្រិតនៃការធានារ៉ាប់រងសុខភាព ជំនួយសុខភាពសង្គម កម្មវិធីធានារ៉ាប់រងសុខភាព និងកម្មវិធីសុខភាពផ្សេងទៀត ។ **ជ្រើសរើសគ្រូពេទ្យព្យាបាលផ្ទាល់របស់ខ្លួន ។**

(11) ព័ត៌មានផ្ទាល់ខ្លួន ព័ត៌មានហិរញ្ញវត្ថុ និងការព្យាបាលត្រូវរក្សាទុកជាការសម្ងាត់ ហើយត្រូវណែនាំអ្នកផ្តល់សេវាអំពីគោលនយោបាយ និងនីតិវិធីទាក់ទងនឹងការបញ្ចេញព័ត៌មាននេះ ។

(12) ត្រូវអនុញ្ញាតឲ្យចូលមើលរបាយការណ៍ ឬសរសេរព័ត៌មាន ចេញពីរបាយការណ៍ ដោយអនុទ្បោមតាមផ្នែកទី144.291 ដល់ 144.298 ។ **របាយការណ៍ពិនិត្យព្យាបាលត្រូវរក្សាទុកជាការសម្ងាត់ ។ ចូលទៅកាន់ ឬបញ្ចេញព័ត៌មានរបស់អ្នកជម្ងឺ និងរបាយការណ៍មន្ទីរពេទ្យត្រូវបានអនុញ្ញាតដោយអនុទ្បោមតាមផ្នែកទី 45 CFR ផ្នែក 160 និង 164 ។**

(13) ត្រូវបានបម្រើដោយបុគ្គលិកដែលត្រូវបានហ្វឹកហាត់ត្រឹមត្រូវ និងមានសមត្ថភាពក្នុងការបំពេញតួនាទីរបស់ខ្លួន ។

(14) ត្រូវបានព្យាបាលដោយសមរម្យ និងរក្សាទុកទ្រព្យសម្បត្តិរបស់អ្នកជំងឺយ៉ាងល្អ ។ ព្យាបាលអ្នកជម្ងឺ និងរក្សាទុកទ្រព្យសម្បត្តិគាត់ល្អសមរម្យ ។

(15) តវ៉ាទាក់ទងនឹងការព្យាបាល ឬការថែទាំ ដែលអនុវត្តមិនបានល្អ ការខកខានមិនបានដាក់វិន័យ ឬទាក់ទងនឹងកង្វះភាពគួរសម ឬគោរពចំពោះអ្នកជម្ងឺ ឬទ្រព្យសម្បត្តិរបស់អ្នកជម្ងឺ **ដោយបុគ្គលណាម្នាក់ ដែលបំពេញសេវាជំនួសមន្ទីរពេទ្យ ។**

**អ្នកជម្ងឺមានសិទ្ធិមិនត្រូវបានរើសអើង ឬសងសឹកសម្រាប់ការអនុវត្តសិទ្ធិរបស់ខ្លួន ។**

(16) មិនត្រូវបានបំពានទោះដោយពាក្យសម្តី និងរាងកាយ ។ **មិនត្រូវទទួលការធ្វើទុក្ខបុកម្នេញ ការធ្វេសប្រហែស ឬរំលោភបំពានដោយផ្ទាល់មាត់ ស្មារតី ផ្លូវភេទ និងរាងកាយ រួមទាំងការធ្វើឲ្យរបួសដោយមិនដឹងប្រភព និងទ្រព្យសម្បត្តិមិនសមរម្យរបស់អ្នកជម្ងឺ ។**

(17) ដោយសមហេតុផល ត្រូវផ្តល់ការជូនដំណឹងជាមុនអំពីការផ្លាស់ប្តូរសេវា ឬតម្លៃ រួមទាំងយ៉ាងហោចណាស់ជូនដំណឹង10 ថ្ងៃមុន មុនពេលបញ្ចប់ការផ្តល់សេវា ដោយអ្នកផ្តល់សេវាលើកលែងតែក្នុងករណីដែល៖
(i) ការទទួលសេវាភ្ជាប់ក្នុងការអនុវត្ត ដែលផ្លាស់ប្តូរលក្ខខណ្ឌការងាររវាងអ្នកផ្តល់សេវាថែទាំចុងក្រោយ និងបុគ្គលដែលផ្តល់សេវាថែទាំ ឬបង្កើតនូវបរិយាកាសការងារដែលមានការរំលោភ និងគ្មានសុវត្ថិភាពសម្រាប់បុគ្គលដែលផ្តល់សេវាថែទាំ
(ii) ការសង្គ្រោះបន្ទាន់សម្រាប់អ្នកផ្តល់សេវាមិនផ្លូវការ ឬការផ្លាស់ប្តូរចាំបាចក្នុងលក្ខខណ្ឌនៃការទទួលយកបង្ហាញលទ្ធផលចំពោះតម្រូវការសេវា ដែលលើសការព្រមព្រៀងផ្តល់សេវាកម្មបច្ចុប្បន្ន ហើយដែលមិនអាចផ្តល់សុវត្ថិភាពដល់អ្នកផ្តល់សេវាថែទាំ ឬ
(iii) ការទទួលគឺមិនត្រូវបានបញ្ជាក់ទៀតទេថាត្រូវបានបញ្ចប់ជម្ងឺ។

(18) ការសម្របសម្រួលផ្ទេរ នៅពេលមានការផ្លាស់ប្តូរអ្នកផ្តល់សេវា។

(19) ដឹងពីរបៀបទាក់ទងនឹងបុគ្គលពាក់ព័ន្ធនឹងអ្នកផ្តល់សេវាដែលទទួលខុសត្រូវក្នុងការដោះស្រាយបញ្ហា និងឲ្យអ្នកផ្តល់សេវាស៊ើបអង្កេត និងព្យាយាមដោះស្រាយបណ្តឹងតវ៉ា ។

(20) ដឹងពីឈ្មោះ និងអាសយដ្ឋាននៃភ្នាក់ងារស្រុក ឬរដ្ឋ ដើម្បីទាក់ទងសុំព័ត៌មានបន្ថែម ឬជំនួយការ ។

(21) អះអាងសិទ្ធិទាំងនេះដោយផ្ទាល់ខ្លួន ឬអះអាងដោយសមាជិកគ្រួសាររបស់អ្នកជម្ងឺ នៅពេលដែលអ្នកជម្ងឺត្រូវបានវិនិច្ឆ័យថាអសមត្ថភាពដោយគ្មានការសងសឹក **ប្រសិនបើអ្នកជម្ងឺត្រូវបានវិនិច្ឆ័យថាអសមត្ថភាពតាមច្បាប់របស់រដ្ឋដោយតុលាការមានយុត្តាធិការត្រឹមត្រូវ សិទ្ធិរបស់អ្នកជម្ងឺត្រូវបានអនុវត្ត បុគ្គលដែលត្រូវបានតែងតាំងស្របតាមច្បាប់របស់រដ្ឋ ដើម្បីអនុវត្តក្នុងនាមអ្នកជម្ងឺ ។ ប្រសិនបើតុលាការរដ្ឋពុំទាន់ត្រូវបានវិនិច្ឆ័យអ្នកជម្ងឺថាអសមត្ថភាពទេ អ្នកតំណាងផ្លូវច្បាប់ដែលចាត់តាំងដោយអ្នកជម្ងឺអនុឡោមតាមច្បាប់របស់រដ្ឋអាចអនុវត្តសិទ្ធិរបស់អ្នកជំងឺតាមទំហំដែលអនុញ្ញាតដោយច្បាប់**

(22) សម្រួលការឈឺចាប់ និងរោគសញ្ញា ដោយគ្រប់គ្រងលើតម្រូវការរបស់អ្នកជម្ងឺដល់កម្រិតដែលងាយស្រួល ។ **ទទួលបានការគ្រប់គ្រងប្រសិទ្ធិភាពនៃការឈឺចាប់ និងត្រួតពិនិត្យរោគសញ្ញាពីអ្នកជម្ងឺសម្រាប់លក្ខខណ្ឌទាក់ទងនឹងការបញ្ចប់ជម្ងឺ**

**មន្ទីរពេទ្យត្រូវ៖**
**(i) ធានាថារាល់ការចោទប្រកាន់ពីការបំពានទាក់ទងនឹងការធ្វើទុក្ខបុកម្នេញការធ្វេសប្រហែល ឬការបំពានដោយពាក្យសម្តី ស្មារតី ផ្លូវភេទ និងរាងកាយ រួមមានការធ្វើឲ្យរបួសដោយមិនដឹងប្រភពការរក្សាទុកទ្រព្យសម្បត្តិរបស់អ្នកជម្ងឺមិនបានល្អដោយបុគ្គលណាម្នាក់ក្នុងការផ្តល់សេវាក្នុងនាមមន្ទីរទេព្យត្រូវរាយការណ៍ជាបន្ទាន់ដោយបុគ្គលិករបស់មន្ទីរពេទ្យ និងបុគ្គលិកជាប់កិច្ចសន្យាទៅរដ្ឋបាលរបស់មន្ទីរពេទ្យ (ii) ស៊ើបអង្កេតភ្លាមៗរាល់ការចោទប្រកាន់ពីការរំលោភពាក់ព័ន្ធនឹងបុគ្គលណាម្នាកក្នុងការផ្តល់សេវាក្នុងនាមមន្ទីរពេទ្យ និងត្រូវចាត់វិធានការភ្លាមៗដើម្បីការពារការរំលោភធ្ងន់ធ្ងរថែមទៀត ខណៈដែលការរំលោភបំពានដែលត្រូវបានចោទប្រកាន់ត្រូវបានដោះស្រាយ ។ ក្នុងការស៊ើបអង្កេត និង/ឬចងក្រងជាឯកសារនៃការបំពានដែលបានចោទប្រកាន់ទាំងអស់ត្រូវអនុវត្តស្របតាមនីតិវិធីដែលបានបង្កើតឡើង (iii) ចាត់វិធានការកែតម្រូវសមស្រប ស្របតាមច្បាប់រដ្ឋ ប្រសិនបើការរំលោភដែលបានចោទប្រកាន់ត្រូវបានបញ្ជាក់ដោយរដ្ឋបាលមន្ទីរពេទ្យ ឬស្ថាប័នខាងក្រៅមានសមត្ថកិច្ច ដូចជាភ្នាក់ងារស្ទង់មតិរដ្ឋ ឬភ្នាក់ងារអនុវត្តច្បាប់មូលដ្ឋាន និង (iv) ត្រូវធានាថា ការរំលោភដែលបានបញ្ជាក់ត្រូវបានរាយ**

**ការណ៍រដ្ឋ ឬស្ថាប័នមូលដ្ឋានដែលមានសមត្ថកិច្ច (មានភ្នាក់នៃការបញ្ជាក់ និងស្ទង់មតិរបស់រដ្ឋ) ក្នុងរយៈពេល 5 ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីបានដឹងដឹងការរំលោភបំពាននេះ ។**

បើអ្នកផ្តល់សេវាមន្ទីរពេទ្យប្រតិបត្តិការមណ្ឌលថែទាំអ្នកជម្ងឺនៃជីវិតចុងក្រោយ សេចក្តីជូនដំណឹងដែលធ្វើជាលាយលក្ខណ៍អក្សរផ្ញើទៅអ្នកជម្ងឺដែលស្នាក់នៅក្នុងមណ្ឌលព្យាបាលមនុស្សចាស់ម្នាក់ៗត្រូវមានបញ្ជាក់អំពីចំនួន និងគុណសម្បត្តិរបស់បុគ្គលិក ទាំងបុគ្គលិកធម្មតា និងបុគ្គលិកស្ម័គ្រចិត្តដែលត្រូវបានជួលដោយអ្នកផ្តល់សេវាស្របតាមលក្ខខណ្ឌនៃវិធាន MN 4664.0390 គ្រប់វេននីមួយៗនៅក្នុងមណ្ឌលថែទាំអ្នកជម្ងឺនោះ ។

ប្រសិនបើលោកអ្នកមានការតវ៉ាចំពោះភ្នាក់ងារ ឬបុគ្គលដែលផ្តល់សេវាស្នាក់នៅដល់លោកអ្នក លោកអ្នកអាចទូរស័ព្ទទៅ សរសេរលិខិតជាលាយលក្ខណ៍អក្សរ ឬ អញ្ជើញទៅកាន់ ការិយាល័យទទួលបន្ទុកសម្រួលបណ្ដឹងផ្នែកសុខាភិលបាល MINNESOTA ។ លោកអ្នកក៏ត្រូវ ទាក់ទងទៅកាន់ការិយាល័យនៃមន្ត្រីចាត់តាំងផ្នែកអង្កេត និងទទួលបណ្ដឹងផ្នែកការថែទាំដែល មានរយៈពេលយូរអង្វែង ។

## ការិយាល័យទទួលបន្ទុកសម្រួលបណ្ដឹង ផ្នែកសុខាភិលបាល

(651) 201-4201

1-800-369-7994

Fax: (651) 281-9796

**អាសយដ្ឋានប៉ុស្តិ៍៖**

ក្រសួងសុខាភិបាលនៃរដ្ឋ Minnesota 2ការរិយាល័យទទួលពាក្យបណ្ដឹង នៃមណ្ឌលសុខភាព

P.O. Box 64970

ផ្លូវ ផូល (Paul) មីនណេសូតា (Minnesota) 55164-0970

TDD/TTY៖ 651-215-8980

**អាសយដ្ឋានការិយាល័យ៖**

មន្ទីរសុខាភិបាលMinnesota

ការិយាល័យទទួលបន្ទុក សម្រួលបណ្ដឹង ផ្នែកសុខាភិលបាល

85 ភាគខាងកើតកន្លែងទី7

ផ្លូវ ផូល (Paul) មីនណេសូតា (Minnesota) 55164-0970

## មន្ត្រីចាត់តាំងផ្នែកអង្កេត និងទទួលបណ្ដឹងផ្នែកការថែទាំដែលមានរយៈពេលយូរអង្វែង

(651) 431-2555

1-800-657-3591

ទូរសារ៖ (651) 431-7452

**អាសយដ្ឋានប៉ុស្តិ៍៖**

មន្ត្រីចាត់តាំងផ្នែកអង្កេតនិងទទួលបណ្ដឹងផ្នែកការថែទាំដែលមានរយៈពេលយូរអង្វែង

ប្រអប់សំបុត្រលេខ 64971

ផ្លូវ Paul MN 55164-0971

**នាមអ្នកទទួលអាជ្ញាប័ណ្ណ៖ ________________________________________________**
**ទូរស័ព្ទ៖ _______________________________________________________________**
**សារអេឡិចត្រូនិក៖ ______________________________________________________**
**អាសយដ្ឋាន៖ ___________________________________________________________**
**នាម/ងារ របស់បុគ្គលដែលជាអ្នកត្រូវទាក់ទងដោយផ្ទាល់ពេលមានបញ្ហាឬមានការតវ៉ា៖**

____________________________________________________________________

សម្រាប់ជាជាព័ត៌មានតែប៉ុណ្ណោះ ហើយមិនមែនជាការបង្គាប់ឲ្យធ្វើនៅក្នុងអត្ថបទសេចក្ដីប្រកាសសិទ្ធិឯកត្តជនស្ដីពីការផ្ដល់សេវាស្នាក់នៅឡើយ៖ ច្បាប់ MN ផ្នែក 144A.751

អនុផ្នែក 2. **ការបកស្រាយ និងការអនុវត្តសិទ្ធិនេះ ។**
សិទ្ធិដែលចែងក្នុងផ្នែកនេះត្រូវបានបង្កើតដើម្បីជាប្រយោជន៍សម្រាប់បុគ្គលដែលទទួលការថែទាំអ្នកជម្ងឺសម្រាប់ជីវិតចុងក្រោយ ។ អ្នកផ្ដល់សេវាស្នាក់នៅមិនស្នើ ឬតម្រូវឲ្យអតិថិជនប្រគល់សិទ្ធិទាំងនេះជាថ្នូរនៃលក្ខខណ្ឌក្នុងការទទួលយកសេវានោះឡើយ ។ អ្នកអាណាព្យាបាល ឬអ្នកថែទាំ ឬក្នុងការណីគ្មានអ្នកអាណាព្យាបាល ឬអ្នកថែទាំបុគ្គលដែលត្រូវបានតែងតាំង អាចស្វែងរកការអនុវត្តសិទ្ធិទាំងនេះបាន ។ សេចក្ដីប្រកាសអំពីសិទ្ធិនេះមិនជំនួស ឬលុបបំបាត់សិទ្ធិ និងសេរីភាពផ្សេងទៀត ដែលអាចមានចំពោះបុគ្គលដែលទទួលនូវការថែទាំសម្រាប់ជីវិតចុងក្រោយ បុគ្គលដែលផ្ដល់ការថែទាំនេះ ឬអ្នកផ្ដល់សេវាថែទាំអ្នកជម្ងឺចុងក្រោយដែលបានការអនុញ្ញាត តាមផ្នែកទី 144A.753 ។

អនុផ្នែក 3. **សេចក្ដីប្រកាស ។** ច្បាប់ចម្លងនៃសិទ្ធិទាំងនេះត្រូវបានផ្ដល់ទៅឲ្យបុគ្គលនោះនៅពេលដែលការថែទាំសុខភាពត្រូវបានចាប់ផ្ដើមអនុវត្ត ។ ច្បាប់ចម្លងត្រូវមានអាសយដ្ឋាន និងលេខទូរស័ព្ទការិយាល័យទទួលពាក្យបណ្ដឹងសុខាភិបាល និងការិយាល័យសង្គ្រោះប្រជាពលរដ្ឋសម្រាប់ការថែទាំរយៈពេលវែង និងការសង្ខេបសេចក្ដីប្រកាសដោយរៀបរាប់អំពីរបៀបដាក់ពាក្យបណ្ដឹងទៅកាន់ការិយាយល័យទាំងនេះ ។ ព័ត៌មានអំពីរបៀបទាក់ទងការិយាល័យសង្គ្រោះពលរដ្ឋសម្រាប់ការថែទាំរយៈពេលវែង ត្រូវបញ្ចូលនៅក្នុងសេចក្ដីជូនដំណឹងអំពីការផ្លាស់ប្ដូរអំពីតម្លៃអ្នកផ្ដល់សេវា និងសេចក្ដីជូនដំណឹងដែលអ្នកថែទាំចាប់ផ្ដើមផ្ទេរ ឬមិនបន្តសេវាកម្ម ។